# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាប្រសិទ្ធិពរលើផ្ទះថ្មីរបស់បងស្រីកូរ៉េនៅភ្នំពេញថ្មី
# ថ្ងៃទី១៤ កុម្ភៈ ២០១៧

អត្ថបទទី១៖ កណ ៦,៥-៨; ៧,១-៥.១០
ដំណឹងល្អ៖ មក ៨,១៤-២១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាឱកាសមួយ ដើម្បីសុំព្រះជាម្ចាស់ប្រទានពរដល់បងស្រី អាទិត្យមុនខ្ញុំបានជួបជាមួយលោកអភិបាលកូរ៉េនៅអ៊ីតាលី នៅជប៉ុន គាត់បានសួរថាតើសាសនាទូតកូរ៉េនៅខ្មែរយ៉ាងមិចដែរ? ខ្ញុំប្រាប់ថាខ្ញុំមានសាសនាទូតកូរ៉េច្រើនក្រុមណាស់នៅខ្មែរ បានយកចិត្តទុកដាក់រៀនភាសាខ្មែរ និងបានយកចិត្តទុកដាក់បំពេញបេសកកម្មដែលបានទទួល។ ថ្ងៃនេះយើងបានស្តាប់អត្ថបទថា **"សាបព្រោះ"** នេះជាជីវិតរបស់សាសនាទូត ជាជីវិតរបស់គ្រីស្តបរិស័ទដែលប្រកាសដំណឹងល្អយ៉ាងទូលំទូលាយ។ អ្នកដែលចេញពីផ្ទះគាត់មិនទៅរើសដីល្អឬមិនល្អ គាត់មិនគិតទេគាត់បានសាបព្រោះ ក្រោយមកមានដីខ្លះទទួលមានដីខ្លះទៀតមិនទទួល ដីដែលទទួលក៏មិនបានមួយរយភាគរយ នេះណែនាំឲ្យយើងនឹកឃើញជីវិតរបស់យើងត្រូវជារបៀបដែលសាបព្រោះ សម្រាប់បងស្រីដែលចូលក្នុងសកម្មភាពផ្នែកសុខភាពភូមិភាគភ្នំពេញ ជាឱកាសមួយដើម្បីតាមរយៈអ្នកជំងឺដែលយើងទទួលមកពីគ្រប់ទីកន្លែង សាបព្រោះព្រះបន្ទូលរបស់ព្រះយេស៊ូ តាមរបៀបដែលយើងយកចិត្តទុកដាក់ តាមរបៀបដែលយើងស្រឡាញ់ តាមរបៀបដែលយើងថៃរក្សា។ ពេលយើងចាប់ផ្តើមសកម្មភាពឲ្យយើងចេះណែនាំអ្នដែលធ្វើការជាមួយយើង ដើម្បីចូលយ៉ាងជ្រៅនៅក្នុងរបៀបដែលព្រះយេស៊ូបានបង្រៀនយើង។ ពេលយើងចង់បង្កើតសកម្មភាពសុខភាព យើងត្រូវតែមើលរបៀបរបស់ព្រះយេស៊ូ ព្រះអង្គបានទៅប្រកាសដំណឹងល្អព្យាបាលទាំងរូបកាយទាំងផ្លូវវិញ្ញាណ ដោយយកចិត្តទុកដាក់នឹងថៃរក្សា។ យើងឃើញស្ត្រីដែលធ្លាក់ឈាម មានមហាជននៅចោមរោមព្រះយេស៊ូ ប៉ុន្តែព្រះយេស៊ូនៅតែចាប់អារម្មណ៍អំពីគាត់ នេះជារបៀបដែលយើងត្រូវតែរៀនការចាប់អារម្មណ៍នឹងយកចិត្តទុកដាក់ជានិច្ច ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះយេស៊ូយាងចូលនៅក្នុងជីវិតមនុស្សទាំងអស់។ ពេលមានថ្លៃ ព្រះជាម្ចាស់អាចប្រមូលបានច្រើន ប្រសិនបើយើងយកចិត្តទុកដាក់នឹងថៃរក្សា។ កន្លែងនេះជាបន្ទប់អធិដ្ឋានឲ្យបងស្រីអធិដ្ឋានដើម្បីយកកម្លាំង ដោយយកចិត្តទុកដាក់ និងថៃរក្សា ដើម្បីផ្តល់សក្ខីភាពអំពីរបៀបព្រះសហគមន៍យើងជាគ្រួសារតែមួយនៅក្នុងអង្គព្រះគ្រីស្ត។

សូមព្រះជាម្ចាស់ប្រទានពរដល់បងស្រី ប្រទានពរដល់បងប្អូនទាំងអស់ ដើម្បីឲ្យយើងទៅជាអ្នកសាបព្រោះយ៉ាងពិសេស ដោយចេះប្រកាសដំណឹងល្អជានិច្ច។ អាម៉ែន។